# สิทธิหน้าที่ นายจ้าง ลูกจ้าง

## សិទ្ធិមុខនាទី

ตามพระราชบัญญัติคุ้มครองแรงงาน
พ.ศ. 2541

តាមច្បាប់ការពារកម្មករ
ឆ្នាំ 1998



ภาษากัมพูชา

ការិយាល័យការពារកម្មករ
នាយកដ្ឋានសុវត្ថិភាពនិងការពារកម្មករ
ក្រសួងការងារ

http://www.labour.go.th

# สิทธิหน้าที่

# นายจ้าง ลูกจ้าง



## 1. រយៈពេលធ្វើការងារធម្មតា

ការងារជាទូទៅមិនលើសពី 8 ម៉ោង/ថ្ងៃ ឬ តាមដែលនិយោជកនិងនិយោជិតព្រមព្រៀងគ្នា ហើយមិនលើសពី 48 ម៉ោង/សប្តាហ៍ ។

ការងារដែលអាចជាគ្រោះថ្នាក់ចំពោះសុខភាព និងសុវត្ថិភាពចំពោះនិយោជិតដូចជាការងារដែលត្រូវធ្វើនៅក្រោមដី ក្រោមទឹក ក្នុងអណ្តូងក្នុងរណ្តៅ ឬនៅទីកន្លែងដែលគ្មានខ្យល់អាកាស ការងារដែលពាក់ព័ន្ធទៅនិងវិទ្យុសកម្ម ការងារផ្សារលោហៈ ការងារដឹកជញ្ជូនវត្ថុគ្រោះថ្នាក់ ការងារផលិតសារធាតុគីមីគ្រោះថ្នាក់ ការងារដែលត្រូវធ្វើដោយគ្រឿងប្រដាប់ ឬគ្រឿងចក្រដែលអ្នកធ្វើបានទទួលនៅភាពញ័ររញ្ជួយដែលអាចជាគ្រឿថ្នាក់ ដែលដោយសភាពការងារងាយទទួលគ្រោះថ្នាក់ខ្ពស់ ទ មានសភាពបរិដ្ឋានការធ្វើការងារលើសពីមាត្រដ្ឋានសុវត្ថិភាពដែលបានកំណត់ទុក ដែលមិនអាចកែសំរួលប្រភពដើមបាន ហើយត្រូវចាត់អោយមានជាការការពារនៅនឹងតួបុគ្គលអោយមានពេលវេលាធ្វើការធម្មតាមិនលើសពី 7 ម៉ោង/ថ្ងៃ និងមិនលើសពី 42 ម៉ោង/សប្តាហ៍ ។

## 2. ពេលវេលាការសំរាក

ក្នុងកំឡុងការធ្វើការងារធម្មតា

យ៉ាងហោចណាស់ក៏ជាង 1 ម៉ោង/ថ្ងៃ បន្ទាប់ពីនិយោជិតធ្វើការងារមកហើយមិនលើសពី 5 ម៉ោងបន្តជាប់គ្នា ឬ អាចព្រមព្រៀងគ្នាសំរាកជារយៈៗក៏បាន ក៏ប៉ុន្តែរួមទាំងអស់ត្រូវមិនតិចជាង 1 ម៉ោង/ថ្ងៃ ។

ការងារនៅក្នុងហាងលក់ម្ហូបអាហារ ឬ ហាងលក់ភេសជ្ជៈដែលបើកលក់ ឬ ផ្តល់សេវាកម្មក្នុងមួយថ្ងៃៗមិនបន្តជាប់គ្នា អាចសម្រាកលើសពី 2 ម៉ោង/ថ្ងៃក៏បាន ។

និយោជកអាចនឹងមិនចាត់ពេលសំរាកក៏បានករណីការងារមានលក្ខណៈ ឬសភាពការងារបន្តជាប់គ្នា ដោយបានទទួលយល់ព្រមពីនិយោជិតឬជាការងារបន្ទាន់ ។

មុនការធ្វើការងារក្រៅម៉ោងបន្ថែម

ករណីដែលអោយនិយោជិតធ្វើការងារក្រៅម៉ោងបន្ថែម បន្តពីរយៈពេលធ្វើការងារធម្មតាយ៉ាងហោចណាស់ក៏ជាង 2 ម៉ោង ត្រូវអោយនិយោជិតសំរាកមុននឹងចាប់ផ្តើមធ្វើការងារក្រៅពេលម៉ោងបន្ថែមយ៉ាងហោចណាស់ក៏ 20 នាទី ។